# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់

## អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

* * * * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០២០១ / ០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០៨០៥ / ៣៨៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យ លេខ នស / រកត / ០២០១ / ០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ពីបេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលហៅកាត់ថា (**ក.ជ.ក.ស.**) ។

## ជំពូកទី ២

## បេសកកម្ម តួនាទី និងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ជាអង្គភាពប្រតិបត្តិ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរង មួយចំនួន តាមការចាំបាច់។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានបេសកកម្មអនុវត្តភារកិច្ចតាមការសម្រេចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (**ក.ជ.ក.ស.**) មានភារកិច្ចដូចតទៅ ៖

-លើកផែនការសកម្មភាពការងាររយៈពេលខ្លី មធ្យម វែង របស់ **ក.ជ.ក.ស.**

-សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ស៊ី-ដ (CEDAW) ជូន **ក.ជ.ក.ស.** ដើម្បីពិនិត្យ និងកែលម្អដាក់ជូនរាជរដ្ឋាភិបាលសម្រេច ហើយផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ

-ពិនិត្យតាមដានស្ថានភាពរបស់ស្ត្រី និងផ្តល់អនុសាសន៍ ដោយផ្អែកលើគោលនយោបាយជាតិ របស់រាជរដ្ឋាភិបាល និងគោលដៅសន្និសីទស្ត្រីពិភពលោក

-ជម្រុញការផ្សព្វផ្សាយខ្លឹមសារអនុសញ្ញា ស៊ី-ដ ឱ្យបានទូលំទូលាយដល់មូលដ្ឋាន

-សិក្សាស្រាវជ្រាវច្បាប់ជាតិ-អន្តរជាតិ បទបញ្ជា វិធានការទាំងឡាយណា ដែលពាក់ព័ន្ធនឹងស្ត្រី ដើម្បីតាមដានវាយតម្លៃ និងលើកអនុសាសន៍

-ធ្វើសហប្រតិបត្តិការ និងសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា អង្គការជាតិ អន្តរជាតិ និង

សង្គមស៊ីវិល ដើម្បីលើកអនុសាសន៍ជូន **គ.ជ.ក.ស.** ពិនិត្យ សម្រេច និងធ្វើជូនរាជរដ្ឋាភិបាល

-ធានានិរន្តរភាព នៃដំណើរការរដ្ឋបាល របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

-គ្រប់គ្រងមន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃ **គ.ជ.ក.ស.**

-គ្រប់គ្រងថវិកា និងសារពើភ័ណ្ឌរបស់អគ្គលេខាធិការដ្ឋាន ដោយអនុលោមតាមការសម្រេចរបស់ **គ.ជ.ក.ស.**

-រៀបចំកិច្ចប្រជុំសាមញ្ញ វិសាមញ្ញ និងបូកសរុបរបាយការណ៍ប្រចាំឆ្នាំ រួមមានការធ្វើកំណត់ហេតុ និងរបាយការណ៍ អំពីសកម្មភាព និងលទ្ធផលការងាររបស់ **គ.ជ.ក.ស.**

-ចងក្រងព័ត៌មាន និងឯកសារទាំងអស់ ដែលពាក់ព័ន្ធទៅនឹងស្ត្រី ។

**មាត្រា ៤.-**

ថវិការបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី រួមមាន :

១-ថវិការដ្ឋ ជាឧបសម្ព័ន្ធនៃថវិកា របស់ក្រសួងកិច្ចការនារី ដែលមានកញ្ចប់ថវិកាដោយឡែករបស់ខ្លួន និងត្រូវស្ថិតនៅក្រោមច្បាប់ ស្តីពីហិរញ្ញវត្ថុ ។ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ **គ.ជ.ក.ស.** ត្រូវលើកគម្រោង និងការពារ កញ្ចប់ថវិកាប្រចាំឆ្នាំ ផ្អែកទៅតាមសកម្មភាពការងាររបស់ខ្លួន ។

២- ជំនួយឧបត្ថម្ភពី អង្គការអន្តរជាតិ ប្រទេសផ្តល់អំណោយ សប្បុរសជនជាតិ និងអន្តរជាតិ ។

ប្រភពចំណូលទាំងអស់ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រៅពីថវិការដ្ឋ ត្រូវបញ្ចូលក្នុងគណនីរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅក្នុងធនាគារ ដែលអនុម័តដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មាន រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ជាអាណាប័ក និងអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាអាណាប័កផ្ទេរសិទ្ធិ ។ ការប្រើប្រាស់ថវិកាក្រៅពីភារកិច្ចដំណើរការប្រចាំថ្ងៃ ត្រូវមានការអនុញ្ញាត ពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានសិទ្ធិប្រើប្រាស់ ត្រា របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានភារកិច្ចលើកសំណើ ស្តីពីការតែងតាំង ផ្ទេរភារកិច្ច ការបញ្ឈប់ពីតំណែងនូវមន្ត្រីថ្នាក់ក្រោម ការជ្រើសរើសមន្ត្រីរាជការដែលមានក្របខ័ណ្ឌស្រាប់ និងបុគ្គលិកជាប់កិច្ចសន្យា ជូនប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ពិនិត្យ និងសម្រេច តាមការចាំបាច់ ។

# ជំពូកទី ៣

## រចនាសម្ព័ន្ធ

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចែកចេញជាបីផ្នែក តាមរចនាសម្ព័ន្ធដូចតទៅ :

-ផ្នែក រដ្ឋបាល និងហិរញ្ញវត្ថុ

-ផ្នែក ផែនការ និងសហប្រតិបត្តិការ

-ផ្នែក នីតិកម្ម

អង្គការលេខរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៨.-**

ផ្នែក ត្រូវបែងចែកជាក្រុមកិច្ចការ ។ ផ្នែកនីមួយៗ ត្រូវបែងចែកយ៉ាងតិច បី ក្រុមកិច្ចការ ។

ការបែងចែកទទួលខុសត្រូវលើក្រុមកិច្ចការនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី តាមសំណើរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

**មាត្រា ៩.-**

ផ្នែកនីមួយៗត្រូវដឹកនាំ គ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។ ការកំណត់អំពីឋានៈរបស់ ផ្នែក និងក្រុមកិច្ចការ រួមមាន :

- ប្រធានផ្នែក មានឋានៈស្មើប្រធាននាយកដ្ឋាន
- អនុប្រធានផ្នែក មានឋានៈស្មើអនុប្រធាននាយកដ្ឋាន
- ប្រធានក្រុមកិច្ចការ មានឋានៈស្មើប្រធានការិយាល័យ
- អនុប្រធានក្រុមកិច្ចការ មានឋានៈស្មើអនុប្រធានការិយាល័យ

**មាត្រា ១០.-**

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ អាចលើកសំណើជូនប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីពិនិត្យ និងសម្រេចលើការបង្កើតអនុគណៈកម្មការជំនាញផ្សេងៗទៀត តាមតម្រូវការចាំបាច់ ។

# ជំពូកទី ៤

## មុខងារ និងភារកិច្ច របស់ផ្នែកនីមួយៗ

**មាត្រា ១១._**

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ច ដូចតទៅ :

- គ្រប់គ្រងមន្ត្រីរាជការ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ចាត់ចែង និងគ្រប់គ្រងឯកសាររដ្ឋបាល របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- រៀបចំ តាក់តែងលិខិតរដ្ឋបាលនានា ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ **ក.ជ.ក.ស.**
- រៀបចំ និងសរុបរបាយការណ៍ លទ្ធផល និងសកម្មភាព របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជាប្រចាំ និងធ្វើការបូកសរុបរបាយការណ៍ប្រចាំឆ្នាំ
- លើកគម្រោងស្នើសុំ ថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ ប្រមូលផ្តុំតម្រូវការនានា និងតាមដានរំលឹកពីការប្រតិបត្តិ
- គ្រប់គ្រងអចលនវត្ថុ ចលនវត្ថុ និងបញ្ជីសារពើភណ្ឌ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ផ្គត់ផ្គង់សម្ភារៈបរិក្ខារដល់អគ្គលេខាធិការដ្ឋាន និងកិច្ចប្រជុំនានា ដែលទាក់ទងនឹង **ក.ជ.ក.ស.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ជូន ។

**មាត្រា ១២._**

ផ្នែកផែនការ និងសហប្រតិបត្តិការ មានភារកិច្ច ដូចតទៅ :

- រៀបចំផែនការសកម្មភាព ការងាររយៈពេលខ្លី មធ្យម វែង របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ពិនិត្យ ប្រមូលទិន្នន័យ និងវិភាគ លើលទ្ធផលការងារទទួលបានពីគ្រប់លំដាប់ថ្នាក់
- គ្រប់គ្រងគេហទំព័រ ដកស្រង់ព័ត៌មានប្រចាំថ្ងៃ និងរាយការណ៍
- និពន្ធ ផលិត និងចងក្រងឯកសារ ផ្សព្វផ្សាយព័ត៌មាន ដោយសហការជាមួយគ្រប់ប្រព័ន្ធផ្សព្វផ្សាយ
- រៀបចំ ផលិត សៀវភៅរូបភាព ផ្ទាំងរូប ខ្ទីមសារស្គត ប័ណ្ណផ្អត់ ដែលទាក់ទងសកម្មភាពការងារ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ទំនាក់ទំនង សម្របសម្រួល និងសហការការងារជាមួយក្រសួង ស្ថាប័ន និងសង្គមស៊ីវិល
- ចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល លើកិច្ចការរបស់ខ្លួន
- រៀបចំពិធីការ និងដំណើរការរាល់កិច្ចប្រជុំ និងជំនួបពិភាក្សាផ្សេងៗ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ជូន។

**មាត្រា ១៣.-**

ផ្នែកនីតិកម្ម មានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ អំពី ច្បាប់ជាតិ បទបញ្ញា វិធានទាក់ទងនឹងស្ត្រី និងចូលរួមធ្វើវិសោធនកម្ម ជាមួយអន្តរក្រសួង សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធ។
- ចូលរួមប្រជុំ តាមដាន វាយតម្លៃ សម្របសម្រួល ផ្តល់អនុសាសន៍ ទៅលើរាល់ការជម្រុញអនុវត្តច្បាប់ជាតិ កិច្ចព្រមព្រៀង អនុស្សរណៈ បទបញ្ញា និងវិធានការទាក់ទងនឹងស្ត្រី
- ពិនិត្យ និងតាមដានវាយតម្លៃ ការអនុវត្តគោលនយោបាយជាតិ ពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ តាមគ្រប់លំដាប់ថ្នាក់ រួមមានថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន ឃុំ សង្កាត់
- តាមដាន វាយតម្លៃ លើការអនុវត្តច្បាប់ជាតិ ដូចជា ច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ លក់ដូរមនុស្ស អំពើធ្វើអាជីវកម្មលើមនុស្ស តាមគ្រប់លំដាប់ថ្នាក់
- ចូលរួមផ្សព្វផ្សាយ និងតាមដាន វាយតម្លៃ លើការអនុវត្តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ
- ប្រមូល និងចងក្រងព័ត៌មាន លើករណីអំពើហិង្សាលើស្ត្រី ដើម្បីរៀបចំសម្របសម្រួលមូលដ្ឋានស្ថិតិឱ្យបានសមស្របតាមបច្ចុប្បន្នភាព
- សិក្សាស្រាវជ្រាវ ច្បាប់ អនុសញ្ញា សិទ្ធិសញ្ញាអន្តរជាតិទាក់ទងនឹងស្ត្រី និងតាមដាន វាយតម្លៃ លើការអនុវត្តច្បាប់នៅកម្ពុជា
- សម្របសម្រួល និងសហការជាមួយ ក្រសួង ស្ថាប័ន សង្គមស៊ីវិលនានា ក្នុងការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស៊ី-ដ នៅកម្ពុជា តាមអនុសាសន៍របស់អង្គការសហប្រជាជាតិ
- ជម្រុញការផ្សព្វផ្សាយអនុសញ្ញា ស៊ី-ដ នៅគ្រប់លំដាប់ថ្នាក់ ដល់មូលដ្ឋាន ឃុំ សង្កាត់
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ប្រគល់ជូន ។

## ជំពូកទី ៥

## ភារកិច្ចរបស់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង

**មាត្រា ១៤.-**

១-ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកបន្ថែមកិច្ចការរបស់ **គ.ជ.ក.ស.** សំដៅលើកកម្ពស់សមត្ថភាពចូលរួម ក្នុងភារកិច្ចទទួលខុសត្រូវតាមជំនាញនីមួយៗ ក្នុងក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីសរសេររបាយការណ៍-ជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស៊ី-ដ និងការផ្សព្វផ្សាយ ព្រមទាំងការសហការចុះតាមដាន វាយតម្លៃ ការអនុវត្តគោល

នយោបាយជាតិ និងច្បាប់ជាតិជាមួយ **គ.ជ.ក.ស.** ដើម្បីអនុវត្តផែនការសកម្មភាពការងារ របស់ **គ.ជ.ក.ស.** នៅតាមខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រៀងៗខ្លួន ។

២-មន្ទីរកិច្ចការនារីគ្រប់ខេត្ត ក្រុង និងជនបង្គោលយេនឌ័រ តាមមន្ទីរនានាជុំវិញខេត្ត ក្រុង ត្រូវទទួលបន្ទុកបន្ថែម កិច្ចការរបស់ **គ.ជ.ក.ស.** ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

អនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៥៧......អនក្រ.បក ចុះថ្ងៃទី ០៥...ខែ មិថុនា...ឆ្នាំ ២០០៧

**ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃ ក.ជ.ក.ស.**

## <u>អង្គការលេខ</u>

## <u>របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី</u>



ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..៥៧......អនក្រ.បក ចុះថ្ងៃទី.០៧.....ខែ.មិថុនា.....ឆ្នាំ ២០០៧
**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក.ជ.ក.ស.**

## អង្គការលេខ

## របស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

